ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ២៣០

ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២

សាលដីកា

លេខ ៣២២ "I"

ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២

# សាលដីកា
# នាមប្រជារាស្ត្រខ្មែរ
# តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២២

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធានអង្គជំនុំជម្រះ

២.ឯកឧត្តម [redacted] ចៅក្រម

៣.ឯកឧត្តម [redacted] ចៅក្រមរបាយការណ៍

៤.ឯកឧត្តម [redacted] ចៅក្រម

៥.លោកជំទាវ [redacted] ចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោក [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើពាក្យបណ្ដឹងសាទុក្ខលេខ ១៨៨ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ របស់លោក [redacted] សង្វារ និងលោកស្រី [redacted] សុធាវិន ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] SUNDAY និង បណ្ដឹងសាទុក្ខលេខ ១៩៧ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] SUNDAY ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៣៨ "ក្រVI.ស.អ" ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន ៖



Scanned with CamScanner

- ជនជាប់ចោទ (អ្នកប្ដឹងសាទុក្ខ) ៖

ឈ្មោះ [redacted]SUNDAY ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិ នីហ្សេរីយ៉ា មុខរបរប្រធានក្រុមហ៊ុន APPROVE GLOBAL CO.LTD ទីកន្លែងកំណើតនៅរដ្ឋKOGI ប្រទេសនីហ្សេរីយ៉ា មានទីលំនៅមុនពេលឃាត់ខ្លួ[redacted]ភូមិសំបូរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោ[redacted](រ) ប្រពន្ធឈ្មោ[redacted](រ) មានកូន ០៣នាក់ ទោសពីមុនគ្មាន (ក្នុងឃុំ) ។

- ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១១៣១ "ង១" ដ.ឃ.ដ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ នៅពន្ធនាគារព្រៃសរ (ម១) ។

- កញ្ញា[redacted] មូលី ជាអ្នកបកប្រែភាសា

- លោក[redacted]សង្វារ និងលោកស្រី[redacted] សុធាវិន ជាមេធាវីការពារសិទ្ធិ

- **ជាប់ចោទពីបទ ៖** ឆបោក និងសំអាតប្រាក់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ រហូតមកដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៨ នៃច្បាប់ស្ដីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**អំពីអង្គហេតុ ៖**

កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ អង្គភាពជំនាញហិរញ្ញវត្ថុនៃនាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនបានទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យរបស់ឈ្មោះ[redacted]សុភា ភេទស្រី អាយុ ៣៣ឆ្នាំ ដែលបានទទួលការផ្ទេរប្រាក់ចូលតាមរយៈធនាគារកម្ពុជាសាធារណៈចំនួនមួយលើក ដែលមានទឹកប្រាក់ចំនួន ២.៥៨០,៦២ (ពីរពាន់ប្រាំរយប៉ែតសិបដុល្លារកៀសហុកសិបពីរ) ដុល្លារអាមេរិក ពីឈ្មោះ [redacted] HOLLINS ដែលមានប្រភពចេញមកពីប្រទេសអូស្ត្រាលី ។ ក្រោយមកនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ ធនាគារកម្ពុជាសាធារណៈបានទទួលសារ SWIFT ពីធនាគារ BANK OF AMERICA របស់សហរដ្ឋអាមេរិកឲ្យបង្វែរប្រាក់ត្រឡប់ទៅវិញ ដោយសារតែប្រតិបត្តិការខាងលើជាប្រតិបត្តិការក្លែងបន្លំ ប៉ុន្តែទឹកប្រាក់ទាំងអស់ត្រូវដកចេញពីគណនីហើយ។ ក្រោយពីទទួលសារ SWIFT នាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនបានបើកការស៊ើបអង្កេតបឋម និងឈានទៅដល់ការឃាត់ខ្លួនឈ្មោះ [redacted]SUNDAY ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិនីហ្សេរីយ៉ា និងឈ្មោ[redacted]សុភា ភេទស្រី អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ តាមដីកាបញ្ជាឲ្យចូលខ្លួនលេខ ០៩៤ អ.យ.ធ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ ក្រោយពីបានសាកសួរឈ្មោះ [redacted] SUNDAY បានឆ្លើយថាខ្លួនចូលមកព្រះរាជាណាចក្រកម្ពុជាហើយ



Scanned with CamScanner

បានបើកក្រុមហ៊ុនឈ្មោះ APPROVE GLOBAL CO.,LTD និងមានគណនីផ្ទាល់ខ្លួនលេខ ០០០៨០៨ ៦៦០ របស់ធនាគារវឌ្ឍនៈអាស៊ី (ABA) ដោយទទួលប្រាក់ពីក្រៅប្រទេសជាច្រើនដូចជាប្រទេសចិន ប្រទេសកូរ៉េ និងប្រទេសនៅសមាគមអ៊ឺរ៉ុប ។ នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ឈ្មោះ [redacted] SUNDAY បានទទួលប្រាក់ចំនួន ៣០.០០០ (សាមសិបពាន់)ដុល្លារអាមេរិក ពីឈ្មោះ [redacted] MARIES ប៉ុន្តែឈ្មោះ [redacted] MARIES បានប្រាប់ថាឱ្យឈ្មោះ [redacted] SUNDAY យកប្រាក់ទាំងនេះទៅឱ្យឈ្មោះ [redacted] PHILLIP ស្នាក់នៅប្រទេសកម្ពុជា ។ ឈ្មោះ [redacted] SUNDAY ក៏ប្រគល់ប្រាក់ទាំងនេះ តាមការណែនាំរបស់ឈ្មោះ [redacted] MARIES នៅចំណុចស្ទឹងមានជ័យថ្មី ចំណែកឈ្មោះ [redacted] សុភា ត្រូវបានឈ្មោះ [redacted] HOLLINS ដែលត្រូវជាបងប្អូនថ្លៃរបស់ឈ្មោះ [redacted] ENEOJO SUNDAY នៅប្រទេសអូស្ត្រាលីផ្ទេរប្រាក់ចំនួន ២.៥៨០,៦២ (ពីរពាន់ប្រាំរយប៉ែតសិបដុល្លារ) ដុល្លារអាមេរិកចូលក្នុងគណនីរបស់ឈ្មោះ [redacted] សុភា មែនប៉ុន្តែពុំទាន់បានដកប្រាក់ផង ស្រាប់តែគណនីនេះត្រូវបានដកប្រាក់ចេញវិញ។ ក្រោយមកឈ្មោះ [redacted] SUNDAY ធ្លាប់បានទទួលបានការផ្ទេរប្រាក់ពីអតិថិជនឈ្មោះ [redacted] KIM ជនជាតិកូរ៉េខាងត្បូងសរុបចំនួន ៤៨០(បួនរយប៉ែតសិប)ដុល្លារអាមេរិក ផងដែរ ដោយស្គាល់គ្នាតាមរយៈធនាគារឱ្យទៅជនជាប់ចោទដោយគោលបំណងដើម្បីបំលែងប្រាក់នេះទៅជាផលប្រយោជន៍របស់ខ្លួន ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤០៣៤ "ខ១" ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចមានដូចតទៅ៖

១-ផ្តន្ទាទោស៖

១.១-ឈ្មោះ [redacted] SUNDAY ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិនីហ្សេរីយ៉ា ដែលមានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារកំណត់ ៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤០០.០០០.០០០ (បួនរយលាន) រៀល ។

១.២-ឈ្មោះ [redacted] សុភា ភេទស្រី អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ ដែលមានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារកំណត់ ២ (ពីរ)ឆ្នាំ តែទោសនេះត្រូវព្យួរទាំងស្រុង តាមបញ្ញត្តិស្តីពីការព្យួរទោសធម្មតានៃក្រមព្រហ្មទណ្ឌ និងពិន័យជាប្រាក់ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល។

ពីបទ ឆបោក និង សំអាតប្រាក់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ រហូតមកដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៨ នៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទាន ភេរវកម្ម។



Scanned with CamScanner

២-រឹបអូសវត្ថុចាប់យក និងទ្រព្យសម្បត្តិដូចខាងក្រោម៖

-ទូរស័ព្ទដៃម៉ាក Olitech ពណ៌ខ្មៅ ចំនួន ០១ (មួយ) គ្រឿង (មិនដំណើរការ) ។

-ទូរស័ព្ទដៃម៉ាក SUMSUNG G8 PLUS ពណ៌ខៀវ ចំនួន ០១ (មួយ) គ្រឿង (មិនដំណើរការ) ។

-ខ្សែកលោហធាតុ ពណ៌លឿងចំនួន ០១ (មួយ) ខ្សែ ។

-នាឡិការដៃម៉ាក DIESEL ពណ៌ទឹកមាស ចំនួន ០១ (មួយ) គ្រឿង (មិនដំណើរការ) ។

៣-រឹបអូសប្រាក់សរុបចំនួន ៣០.៥៩៧,២៦ (សាមសិបពាន់ប្រាំរយកៅសិបប្រាំពីរដុល្លារអាមេរិក ម្ភៃប្រាំមួយសេន) ដែលរក្សាទុកក្នុងគណនីធនាគារដោយក្នុងនោះ៖

-ប្រាក់ចំនួន ៣០.៥៤០,៥៥$ (សាមសិបពាន់ប្រាំរយសែសិបដុល្លារអាមេរិក និងហាសិបប្រាំសេន) បន្សល់ទុកនៅក្នុងគណនីធនាគារលេខ ០០០៨០៨៦៦០ ចេញដោយ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់** ដែលមានជនជាប់ចោទឈ្មោះ [redacted] SUNDAY ជាម្ចាស់គណនី ។

-ប្រាក់ចំនួន ៥៨,០៧$ (សែសិបប្រាំបីដុល្លារអាមេរិក សូន្យប្រាំពីរ) បន្សល់ទុកនៅក្នុងគណនីធនាគាររបស់ជនជាប់ចោទឈ្មោះ [redacted] សុភា ដោយក្នុងនោះប្រាក់ចំនួន ០,០៣ (សូន្យក្បៀស និងសូន្យបីសេ) បន្សល់ទុកនៅក្នុងគណនីធនាគារលេខ ០០០៥១៤៣១០ ចេញដោយ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់** ប្រាក់ចំនួន ១៦,៣៧ (ដប់ប្រាំមួយដុល្លារអាមេរិក និងសាមសិបប្រាំពីរសេន) បន្សល់ទុកនៅក្នុងគណនីធនាគារលេខ ២០១០០១១០០០០២១៨៣១ ចេញដោយ **ធនាគារ អ អេច ប៊ី** ប្រាក់ចំនួន ១០,០០$ (ដប់ដុល្លារអាមេរិក) បន្សល់ទុកនៅក្នុងគណនីធនាគារលេខ ៤៣៩០០២៨ ចេញដោយ **ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់** ប្រាក់ចំនួន ១១,៦៧$ (ដប់មួយដុល្លារអាមេរិក និងហុកសិបប្រាំពីរសេន) បន្សល់ទុកនៅក្នុងគណនីធនាគារលេខ ២៦០០២៣០០១៦២៦៨ ចេញដោយ **ធនាគារកម្ពុជាសាធារណៈ** និងប្រាក់ចំនួន ១០$ (ដប់ដុល្លារអាមេរិក) បន្សល់ទុកក្នុងគណនីធនាគារដែលមានលេខ ០៨០០០០៩៥៣៨៥០ ចេញដោយ **ធនាគារសាខមប៉ើង**។

-និងប្រាក់ចំនួន ៨.៦៤$ (ប្រាំបីដុល្លារអាមេរិក និងហុកសិបបួនសេន) ទៀតបន្សល់ទុកនៅក្នុងគណនីធនាគាររបស់ក្រុមហ៊ុនឈ្មោះ APPROVE GLOBAL CO., LTD ដែលមានគណនីលេខ ០០១២៥២៤០៤ ចេញដោយ **ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់** ។

៤-ប្រគល់វត្ថុចាប់យក៖

-លិខិតឆ្លងដែនលេខ A៥០២១០៩៤១ ចំនួន ០១ (មួយ) ក្បាល ។

-សៀវភៅការងារជនបរទេស ចំនួន ០១ (មួយ) ក្បាល ។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] SUNDAY និងជនជាប់ចោទឈ្មោះ [redacted] សុភា និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១១៣២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ OYINBOSON ENEOJO SUNDAY ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤០៣៤ "ខ១" ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

- បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៣៨ "ក្រVI.ស.អ" ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ១១៣២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់ពិរុទ្ធជនឈ្មោះ [redacted] SUNDAY ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្អែកលើអង្គច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤០៣៤ "ខ១" ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] SUNDAY តាមច្បាប់ ។

៤-សាលដីកានេះបានជំនុំជម្រះនាថ្ងៃទីចន្ទ ១១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នាថ្ងៃព្រហស្បតិ៍ ៥រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២។

ទុកសិទ្ធិសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្តឹងសាទុក្ខលេខ ១៨៨ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ របស់លោក [redacted] សង្វារ និងលោក [redacted] សុធារិន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] SUNDAY និងបណ្តឹងសាទុក្ខលេខ ១៩៧ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] SUNDAY ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៣៨ "ក្រVI.ស.អ" ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

- ចៅក្រមបានអានរបាយការណ៍ ។

- តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា ៖



Scanned with CamScanner

- ការសម្រេចសេចក្ដីរបស់សាលាឧទ្ធរណ៍ភ្នំពេញដែលបានតម្កល់សាលក្រមរបស់សាលាដំបូង ទុកជាបានការដដែល គឺមានសំអាងហេតុ និងភស្តុតាងត្រឹមត្រូវតាមច្បាប់ ព្រោះថា៖

- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] SUNDAY ដែលទទួលស្គាល់អង្គហេតុនៃការផ្ញើប្រាក់មកពីបរទេស ព្រមទាំងលទ្ធផលនៃការស៊ើបអង្កេតរបស់សមត្ថកិច្ចនាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន បង្ហាញឱ្យឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើដូចបទចោទពិតមែន ដូចមានក្នុងសំអាងហេតុចំណុចទី២ ទី៣ ទី៥ ទី៦ និងទី៧ នៃសាលដីកាសាលាឧទ្ធរណ៍ស្រាប់ ។

**ហេតុដូច្នេះ**

**តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច**

- សុំតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៣៨ "ក្រVI.ស.អ" ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

+ ជនជាប់ចោទឈ្មោះ [redacted] SUNDAY បានឆ្លើយថា ខ្លួនអាយុ ៥៧ឆ្នាំ ជនជាតិ នីហ្សេរីយ៉ា ខ្លួនអត់ចង់ខាតពេលវេលា ខ្លួនប្ដឹងមកនេះសូមឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួន សព្វថ្ងៃខ្លួនជាជនជាតិបរទេស ខ្លួនមានជំនួញនៅប្រទេសកម្ពុជា ។ ក្នុងរឿងនេះខ្លួនមិនបានប្រព្រឹត្តទេ ខ្លួនជាអ្នកជំនួញត្រូវគេចោទប្រកាន់ខ្លួនពីបទ សម្អាតប្រាក់ និងបទ ឆបោក ខ្លួនជាជនរងគ្រោះ មេត្តាបន្ធូរបន្ថយទោសដល់ខ្លួន ។

+ លោកស្រី [redacted] សុធាវិន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] SUNDAY បានធ្វើសេចក្ដីសន្និដ្ឋានថា តាមអង្គហេតុដែលសាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ភ្នំពេញសន្មតថាជាអំពើ សម្អាតប្រាក់ នោះហាក់ពុំមានភាពស្របគ្នា និងធាតុនីត្យានុកូលភាពនោះឡើយ ជាក់ស្ដែង ធាតុផ្សំសម្ភារៈដែលសន្មតនៅក្នុងអំពើសម្អាតប្រាក់ផ្សេង អង្គហេតុដែលសន្មតថាជាអំពើសម្អាតប្រាក់នោះផ្សេង ។ អង្គហេតុដែលកើតឡើងនៅក្នុងរឿងក្ដីនេះ គឺកើតឡើងនៅក្នុងឆ្នាំ២០១៨ ហើយច្បាប់សម្រាប់អនុវត្តចំពោះអង្គហេតុនោះគឺក្រមព្រហ្មទណ្ឌ ផ្ទុយទៅវិញ សាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ភ្នំពេញបានយកច្បាប់ស្ដីពីការសម្អាតប្រាក់ឆ្នាំ២០២០ យកមកអនុវត្ត ដែលចំណុចនេះឃើញថា ការអនុវត្តខុសច្បាប់ ហើយមានសភាពផ្ទុយនឹងតាមគោលការណ៍ ស្ដីពីការអនុវត្តច្បាប់ដែលស្រាលជាង ។ អង្គហេតុដែលចោទប្រកាន់ខាងលើបើផ្អែកតាមច្បាប់ ស្ដីពីការសម្អាតប្រាក់ ក៏ដូចជាក្រមព្រហ្មទណ្ឌ គឺពុំមានចែងទាល់តែសោះថា អង្គហេតុខាងលើជាបទល្មើសសម្អាតប្រាក់ ដូច្នេះការដែលសាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ភ្នំពេញសម្រេចផ្ដន្ទា



Scanned with CamScanner

ទោសនោះគឺខុសនឹងគោលការណ៍មានបទល្មើស គ្មានទោស កាលបើគ្មានច្បាប់ចែង ។ ដូច្នេះ កូនក្តីខ្លួនពុំមានទោសទេ គ្មានភស្តុតាងដាក់បន្ទុក ហើយអំពើរបស់កូនក្តីខ្លួនពុំមានច្បាប់ចែងនៅឡើយទេ ។

សំណូមពរ ៖ - សុំបដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៣៨ "ក្រVI.ស.អ" ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ។

- សុំឱ្យដោះលែងកូនក្តីខ្លួនឱ្យមានសេរីភាពវិញ ។

+ លោក [redacted] សង្វារ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] SUNDAY បានធ្វើសេចក្តីសន្និដ្ឋានថា សុំឯកភាពតាមសហភាតា ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទនិងសេចក្តីសន្និដ្ឋានមេធាវីការពារជនជាប់ចោទ

-ក្រោយពីបាន ពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៨៨ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ របស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] SUNDAY និងបណ្តឹងសាទុក្ខលេខ ១៩៧ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] SUNDAY ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៤១៧ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២.យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចតម្កល់សាលក្រមសាលាដំបូងភ្នំពេញទុកជាបានការ ដោយមានសំអាងហេតុចាប់ពីចំណុចទី៥ ទី៦ ទី៧ និងទី៨ នៃសាលដីកាបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] SUNDAY ពិតជាបានប្រព្រឹត្តបទល្មើសឆបោក និងសំអាតប្រាក់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ប្រាកដមែន បទល្មើសនេះមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៨ នៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម សំអាងហេតុនេះមានមូលដ្ឋានភស្តុតាង និងច្បាប់គ្រប់គ្រាន់ នាំឲ្យតុលាការកំពូលជឿជាក់បាន និងឯកភាពតាមសំអាងហេតុនេះ ដោយពុំចាំបាច់សរសេរបញ្ជាក់ឡើងវិញទេ ។



Scanned with CamScanner

៣.យល់ឃើញថា តាមមូលហេតុនៃបណ្ដឹងសាទុក្ខក្នុងសារណាការពារ និងសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនៅចំពោះមុខតុលាការកំពូលបានលើកឡើងថា យោងតាមអង្គហេតុដែលសាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ភ្នំពេញថាជាអំពើសំអាតប្រាក់នោះ ហាក់ពុំមានភាពស្របគ្នា និងធាតុនីត្យានុកូលឡើយ ជាក់ស្ដែងធាតុផ្សំសម្ភារៈដែលសន្មត់ក្នុងអំពើសំអាតប្រាក់ផ្សេង អង្គហេតុដែលសន្មត់ថាជាអំពើសំអាតប្រាក់នោះផ្សេង នោះជាការពុំត្រឹមត្រូវទេ ដោយហេតុថា តុលាការកំពូលបានលើកបញ្ជាក់ក្នុងសំអាងហេតុទី២ ខាងលើនេះរួចហើយ ។ ចំពោះការលើកឡើងថា អង្គហេតុនេះកើតឡើងនៅឆ្នាំ២០១៨ ត្រូវយកក្រមព្រហ្មទណ្ឌមកអនុវត្តនោះជាការពុំត្រឹមត្រូវទេ ដោយហេតុថា អង្គហេតុនេះកើតឡើងនៅឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២១ ទើបបញ្ចប់ ។ ការអនុវត្តច្បាប់របស់តុលាការអង្គសេចក្ដីដោយតុលាការយកមាត្រា ៣៨ នៃច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម មិនប៉ះពាល់ដល់ច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០១៣ និង ឆ្នាំ២០២០ នោះទេ ដោយហេតុថា វិសោធនកម្មលើច្បាប់ឆ្នាំ២០១៣ តែលើមាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ឆ្នាំ២០១៣ តែប៉ុណ្ណោះ ។

៤.យល់ឃើញថា សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ សុំឱ្យតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការដដែលនោះមានសំអាងហេតុ និងភស្តុតាងត្រឹមត្រូវតាមច្បាប់ ។

៥.យល់ឃើញថា មូលហេតុនៃសាទុក្ខរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងជនជាប់ចោទពុំត្រូវនឹងចំណុចណាមួយនៃមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ដែលគប្បីសម្រេចបដិសេធបណ្ដឹងសាទុក្ខនេះចោលទាំងស្រុង និងសម្រេចតម្កល់សាលាដីការបស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការតាមមាត្រា ៤៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៦.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៣៨ " ក្រVI.ស.អ " ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្ដីមកនេះ ត្រឹមត្រូវតាមគតិច្បាប់ ។

## ហេតុដូច្នេះ
## សម្រេចសេចក្តី

១.បដិសេធ បណ្ដឹងសាទុក្ខលេខ ១៨៨ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ របស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] SUNDAY និងបណ្ដឹងសាទុក្ខលេខ ១៩៧ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] SUNDAY ។

២.តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ ៣៨ " ក្រVI.ស.អ " ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការទាំងមូល ។



Scanned with CamScanner

សាលដីកានេះជំនុំជម្រះ និងប្រកាសនៅសាលសវនាការជាសាធារណៈនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

.................................................................................................................................

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ថ្ងៃព្រហស្បតិ៍ ១ រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃព្រហស្បតិ៍ ១ រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២២

**ប្រធានអង្គជំនុំជម្រះ**

[redacted]

"យើង [redacted] ថាវរ៉ូ ក្រឡាបញ្ជីតុលាការកំពូល បញ្ជាក់ថា សាលដីកានេះបានចូលជាស្ថាពរ នៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២២ និងមានអានុភាពអនុវត្ត តាមច្បាប់ ។"

**"សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលដីកាឱ្យសម្រេចតាមសាលដីកានេះ និងឱ្យអាជ្ញាធរគ្រប់តំណែង គ្រប់ថ្នាក់ជួយអនុវត្តសាលដីកានេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។"**

ថ្ងៃព្រហស្បតិ៍ ១ រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner